## និក្ខមនំ Exodus

កណ្ឌនិក្ខមនំនិទានអំពីព្រះសង្គ្រោះរាស្ត្ររបស់ទ្រង់ ដែលជាជនជាតិអ៊ីស្រាអែល ចេញពីទាសភាពនៅក្នុងស្រុកអេស៊ីព្ទ។ កណ្ឌនេះបន្តនិទានរឿងពីកណ្ឌលោកុប្បត្តិ ដែលបានបញ្ចប់ត្រឹមជនជាតិអ៊ីស្រាអែលនៅក្នុងស្រុកអេស៊ីព្ទ។

អេស៊ីព្ទបានសង្កត់សង្កិនពួកគេ ហើយព្រះបានសង្គ្រោះពួកគេ។ ការសង្គ្រោះពួកគេចេញពីស្រុកអេស៊ីព្ទគឺជាការបំពេញសំរេចសេចក្តីសន្យាផ្សេងៗ ដែលទ្រង់បានប្រទានអោយតាំងពីរាប់រយឆ្នាំមុន (លោកុប្បត្តិ ១៥:១៣-១៤)។

ព្រះបានដឹកនាំរាស្ត្ររបស់ទ្រង់ឆ្លងកាត់ទីរហោស្ថានទៅកាន់ភ្នំស៊ីណាយ ជាកន្លែងដែលទ្រង់បានប្រទានក្រិត្យវិន័យដល់ពួកគេ ហើយបានរៀបចំពួកគេសំរាប់ជីវិតថ្មីរបស់ពួកគេនៅក្នុងស្រុកកាណាន ដែលជាទឹកដីសន្យា។

ម៉ូសេគឺជាអ្នកដឹកនាំរបស់ជនជាតិអ៊ីស្រាអែល។ គាត់បានកើតជាសាសន៍ហេព្រើរម្នាក់ បានធំធាត់ឡើងជាបុត្រាសាសន៍អេស៊ីព្ទ ហើយមានការងារជាអ្នកគង្វាលចៀម។ គាត់មានអ្នកជំនួយជាបងប្រុសរបស់គាត់ ឈ្មោះអើរ៉ុន ដែលបានធ្វើជាអ្នកនាំពាក្យរបស់ម៉ូសេ ហើយក្រោយមកទៀតបានក្លាយជាសម្តេចសង្ឃទីមួយរបស់ជនជាតិអ៊ីស្រាអែល។

## សារៈសំខាន់នៃកណ្ឌនិក្ខមនំ Importance of Exodus

កណ្ឌនិក្ខមនំពិតជាសំខាន់ខ្លាំងណាស់ ពីព្រោះ

១. កណ្ឌនេះបង្រៀនច្រើនអំពីព្រះ អំណាចរបស់ទ្រង់ ភាពបរិសុទ្ធរបស់ទ្រង់ សេចក្តីស្មោះត្រង់របស់ទ្រង់ចំពោះសម្ព័ន្ធមេត្រី សិរីល្អរបស់ទ្រង់ និងផែនការណ៍របស់ទ្រង់។

២. ព្រះសង្គ្រោះអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទគឺសកម្មភាពសង្គ្រោះដ៏អស្ចារ្យនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលអ៊ីស្រាអែលត្រូវតែនឹកចាំ ហើយបានប្រទានអោយអ៊ីស្រាអែលមានអត្តសញ្ញាណជារាស្ត្រដែលព្រះបានសង្គ្រោះនិងលោះ ដើម្បីអោយពួកគេត្រូវតែបំរើទ្រង់ (ទំនុកដំកើង ៧៨:៩-១៦, ៤០-៥៥; ៨០:៨; ៨១:១០; ១០៥:២៣-៤៥; ១០៦:៦-២៣; ១១៤:១-២; ១៣៦:១០-១៦)។

៣. កណ្ឌនេះកត់ត្រាក្រិត្យវិន័យទាំងដប់ និងបញ្ញត្តិដទៃៗទៀត ដែលបានបង្ហាញអ៊ីស្រាអែលអំពីមាគ៌ាដែលពួកគេត្រូវដើរតាម ក្នុងនាមជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ទ្រង់ និងនៅក្រោមការគ្រប់គ្រង និងព្រះពររបស់ព្រះ។

៤. កណ្ឌនេះផ្តល់មូលដ្ឋានគ្រឹះមួយសំរាប់ការយល់អំពីព្រះគម្ពីរសញ្ញាថ្មីនិងអ្វីដែលព្រះយេស៊ូវបានធ្វើសំរាប់យើង តាមរយៈការសុគតនិងរស់ឡើងវិញម្តងទៀត។

## ប្រវត្តិសាស្ត្រដែលត្រូវបានកត់ត្រាទុកក្នុងកណ្ឌនិក្ខមនំ The history recorded in Exodus


អាសន្នរោគ(គ្រោះកាច)ទាំងដប់

ព្រះជាម្ចាស់បានត្រាស់ហៅលោកម៉ូសេនៅភ្នំហោរែប ដោយព្រះបន្ទូលថា ព្រះអង្គចាត់លោកម៉ូសេអោយទៅជួបស្តេចផារ៉ោន ដើម្បីអោយបាននាំជនជាតិអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់ព្រះ ចេញពីស្រុកអេស៊ីព្ទ។ ស្តេចផារ៉ោនមិនព្រម អនុញ្ញាត្តអោយអ៊ីស្រាអែលចាកចេញទៅឡើយ ដូច្នេះព្រះអង្គធ្វើអោយកើតមានអាសន្នរោគទាំងដប់នៅក្នុងស្រុកអេស៊ីព្ទ។


បុណ្យរំលងថ្វាយព្រះយេហូវ៉ា (ពិធីបុណ្យចម្លងថ្វាយព្រះអម្ចាស់)


សំដេចសង្ឃ
(មហាបូជាចារ្យ)

នៅពេលអាសន្នរោគទីដប់ (កូនច្បងបានស្លាប់) កើតឡើង ពួកអ៊ីស្រាអែលបានធ្វើបុណ្យរំលងថ្វាយព្រះជាម្ចាស់។

បន្ទាប់ពីពេលនោះ ព្រះអង្គបានរំដោះពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ ហើយពួកគេធ្វើដំណើរទៅស៊ីណាយ។ នៅស៊ីណាយ ព្រះជាម្ចាស់បានប្រទានក្រិត្យវិន័យនិងច្បាប់អំពីសម្តេចសង្ឃនិងរោងឧបោសថដល់ពួកគេ។


រោងឧបោសថគឺជាទីបរិសុទ្ធ

## គម្រោង Outline

ទាសភាពរបស់ជនជាតិអ៊ីស្រាអែល និងកំណើតរបស់ម៉ូសេ (១:១-២:២៥)

ព្រះត្រាស់ហៅម៉ូសេ (៣:១-៤:៣១)

ការចាកចេញដ៏ធំ (៥:១-១៥:២១)

ដំណើរនៅក្នុងទីរហោស្ថាន (១៥:២២-១៨:២៧)

ការប្រទានក្រិត្យវិន័យ (១៩:១-២៤:១៨)

រោងឧបោសថ និងពួកសង្ឃ (២៥:១-៣១:១៨)

ការបះបោរ និងការវិនិច្ឆ័យ (៣២:១-៣៤:៣៥)

ការសាងសង់រោងឧបោសថ (៣៥:១-៤០:៣៨)

## របៀបអានកណ្ឌនិក្ខមនំ How to read Exodus

ដើម្បីយល់និងអនុវត្តកណ្ឌនិក្ខមនំអោយបានត្រឹមត្រូវ ជាការសំខាន់យើងត្រូវយល់អំពីកណ្ឌនេះនៅក្នុងបរិបទដើមរបស់វា នៅក្នុងប្រវត្តិសាស្រ្ត និងនៅក្នុងព្រះគម្ពីរទាំងមូល។ ដើម្បីយល់ចំនុចទាំងបីនេះ យើងត្រូវឆ្លើយនឹងសំនួរប្រាំ។

១. តើកណ្ឌនិក្ខមនំទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?
២. តើគោលបំណងរបស់កណ្ឌនិក្ខមនំសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?
៣. តើកណ្ឌនិក្ខមនំទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?
៤. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីព្រះ?
៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

### ១. តើកណ្ឌនិក្ខមនំទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?

ព្រះគម្ពីរគឺជារឿងធំមួយ ដែលពន្យល់អំពីផែនការណ៍របស់ព្រះ ចាប់ពីការបង្កបង្កើតដល់ការបង្កបង្កើតថ្មី។ ទ្រង់បានបង្កើតរបស់សព្វសារពើជាល្អពីដំបូង ដោយមានអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន។ ពួកគេគឺជារាស្រ្តរបស់ព្រះ រស់នៅទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ ពួកគេមិនបានស្តាប់បង្គាប់ព្រះ ហើយត្រូវបានព្រះបណ្តេញចេញពីសួនច្បារ ដែលជាទីបរិសុទ្ធរបស់ព្រះ។ ផ្នែកទាំងអស់ទៀតនៃព្រះគម្ពីរនិយាយអំពីផែនការណ៍របស់ព្រះ ដើម្បីសង្គ្រោះមនុស្សចេញពីលទ្ធផលនៃការបះបោរនេះ ហើយស្តានគររបស់

ទ្រង់ និងរាស្ត្ររបស់ទ្រង់ ដែលរស់នៅក្នុងទីកន្លែងរបស់ព្រះ នៅក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះឡើងវិញ។ ដូច្នេះ ព្រះបានជ្រើសរើសអ័ប្រាហាំ ហើយបានសន្យាថា ទ្រង់នឹងធ្វើអោយគាត់ក្លាយទៅជាជាតិសាសន៍ធំមួយ ហើយពួកគេនឹងទទួលបានទឹកដីសន្យា។ ពួកគេត្រូវតែជារាស្ត្ររបស់ព្រះ រស់នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ ទ្រង់នឹងគង់ក្នុងចំណោមពួកគេ ដូច្នេះ អ៊ីស្រាអែលនៅទឹកដីសន្យា ដែលជាអេដែនថ្មី និងទីបរិសុទ្ធថ្មី។

ប៉ុន្តែមុនពេលពួកគេអាចចូលទៅក្នុងទឹកដីសន្យាបាន ព្រះបានព្រមានថា ពួកគេនឹងក្លាយជាទាសករនៅក្នុងប្រទេសដទៃអស់រយៈពេល៤០០ឆ្នាំ (លោកុប្បត្តិ ១៥:១៣)។ គ្រួសាររបស់យ៉ាកុប (មានឈ្មោះ «អ៊ីស្រាអែល» ផងដែរ) បានភៀសខ្លួនទៅកាន់អេស៊ីព្ទ ដើម្បីគេចចេញពីគ្រោះរាំងស្ងួតនៅក្នុងស្រុកកំណើតរបស់ខ្លួន ដែលជាកាណាន។ កូនប្រុសរបស់យ៉ាកុបម្នាក់ យ៉ូសែប បាននៅក្នុងអេស៊ីព្ទរួចទៅហើយ មានតំណែងជាមន្ត្រីទទួលបន្ទុកកិច្ចការគ្រោះរាំងស្ងួត។ ដោយដឹងគុណដល់យ៉ូសែប ស្តេចអេស៊ីព្ទ («ផារ៉ោន») បានអញ្ជើញយ៉ាកុបនិងកូនប្រុសដទៃទៀតរបស់គាត់អោយមករស់នៅជាមួយក្រុមគ្រួសារនិងហ្វូងសត្វរបស់ពួកនៅក្នុងស្រុកកូសែន ដែលជាស្រុកមានជីជាតិ។ នៅដើមដំបូងនៃកណ្ឌនិក្ខមនំ ស្ថានភាពមិនភាពខុសគ្នាខ្លាំងណាស់។ យ៉ាកុបនិងយ៉ូសែបបានស្លាប់អស់រយៈពេលជាច្រើនឆ្នាំ ហើយជនជាតិអេស៊ីព្ទបានភ្លេចពួកគេ។ ជនជាតិអេស៊ីព្ទបានត្រឡប់ជាម៉ឺងម៉ាត់ចំពោះជនជាតិអ៊ីស្រាអែលដែលកើនចំនួនច្រើននៅក្នុងប្រទេសរបស់ពួកគេ។ ចំនួនកើនឡើងច្រើនរបស់ជនជាតិអ៊ីស្រាអែល (និក្ខមនំ ១:៧) បង្ហាញថា ព្រះបានកំពុងបំពេញសំរេចសេចក្តីសន្យារបស់ទ្រង់ជាមួយអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប (លោកុប្បត្តិ ១២:២; ១៥:៥; ២២:១៧; ២៦:៤)។

លើសពីនេះ ព្រះបានសន្យានឹងប្រទានពរដល់លោកិយ តាមរយៈអ័ប្រាហាំនិងពូជពង្សរបស់គាត់។ តើការនេះនឹងកើតឡើងយ៉ាងដូចម្តេច? និក្ខមនំ ១៩:៤-៦ ជួយពន្យល់អំពីការនេះ។ អ៊ីស្រាអែលត្រូវធ្វើជាអំបិលនិងពន្លឺសម្រាប់លោកិយ ហើយនេះគឺជាតួនាទីរបស់ពួកគេ។

ទំនាក់ទំនងមួយទៀតរវាងលោកុប្បត្តិ ១-៣ និងកណ្ឌនិក្ខមនំគឺ លោកុប្បត្តិ ៣:១៥។ ព្រះបានមានបន្ទូលថា នឹងមានភាពជាខ្មាំងសត្រូវគ្នារវាងពូជរបស់សត្វពស់និងពូជរបស់ស្រ្តី។ ពេញក្នុងប្រវត្តិសាស្រ្តក្នុងព្រះគម្ពីរ ភាពជាខ្មាំងសត្រូវនេះត្រូវបានមើលឃើញនៅក្នុងការប្រឆាំងរបស់លោកិយចំពោះរាស្ត្ររបស់ព្រះ។ ភាពខ្មាំងសត្រូវនេះត្រូវបានមើលឃើញយ៉ាងច្បាស់នៅក្នុងការប្រឆាំងរបស់ផារ៉ោនចំពោះព្រះនិងរាស្ត្ររបស់ព្រះ។

ចំនុចទាំងអស់នេះសំខាន់ណាស់ ដើម្បីយល់អំពីកណ្ឌនិក្ខមនំ ពីព្រោះជារឿយៗយើងអានកណ្ឌនេះ ដោយគិតថា វាគឺជាសេចក្តីបង្គាប់ដែលយើងត្រូវស្តាប់បង្គាប់តាម។ ទោះជាការពិតដែលកណ្ឌនិក្ខមនំមានការអនុវត្ត

សំខាន់ៗជាច្រើនសំរាប់គ្រីស្ទបរិស័ទក៏ដោយ ក៏យើងត្រូវតែយល់ថា កណ្ឌនេះត្រូវបានអោយដល់អ៊ីស្រាអែលជាដំបូង ហើយមិនគ្រាន់តែប្រាប់អោយពួកគេស្តាប់បង្គាប់តាមប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះទៅទៀត ប្រាប់ពួកគេអំពីភាពអស្ចារ្យរបស់ព្រះ ផែនការណ៍របស់ទ្រង់ សេចក្តីស្មោះត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់ជាមួយអ័ប្រាហាំ និង*របៀបដែលពួកគេគួរតែរស់**នៅក្នុងទឹកដី**ដែលព្រះបានសន្យាប្រទានដល់អ៊ីស្រាអែល*។ ដូច្នេះ យើងគួរតែប្រយ័ត្នអំពីរបៀបអនុវត្តបទគម្ពីរផ្សេងៗនៅក្នុងកណ្ឌនិក្ខមនំមកកាន់យើង ដែលជាគ្រីស្ទបរិស័ទ នៅសព្វថ្ងៃនេះ។ សំខាន់បំផុតនោះ កណ្ឌនេះបង្ហាញប្រាប់យើងថា ព្រះបានសង្គ្រោះអ៊ីស្រាអែល ដោយយោងទៅតាមព្រះគុណនិងសេចក្តីសន្យារបស់ទ្រង់ មិនមែនដោយសារការស្តាប់បង្គាប់របស់ពួកគេឡើយ។ ទ្រង់បានសង្គ្រោះពួកគេចេញពីស្រុកអេស៊ីព្ទរួចហើយ មុនពេលទ្រង់បានប្រទានក្រិត្យវិន័យដល់ពួកគេ។ ប៉ុន្តែដោយសារព្រះបានសង្គ្រោះពួកគេ នោះពួកគេគួរតែរស់នៅជារាស្ត្ររបស់ទ្រង់។ នេះគឺជាគោលការណ៍ ដែលគ្រីស្ទបរិស័ទត្រូវអនុវត្តតាមនៅសព្វថ្ងៃនេះ។ ព្រះបានសង្គ្រោះយើង ដោយយោងទៅតាមព្រះគុណនិងសេចក្តីសន្យារបស់ទ្រង់ គឺតាមរយៈព្រះយេស៊ូវ មិនមែនតាមរយៈការ ស្តាប់បង្គាប់របស់យើងឡើយ។ ហើយដោយសារព្រះបានសង្គ្រោះយើង នោះយើងគួរតែរស់នៅជារាស្ត្ររបស់ ទ្រង់។

## ២. តើគោលបំណងរបស់កណ្ឌនិក្ខមនំសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

ដូចដែលបានលើកឡើងខាងលើហើយថា កណ្ឌនិក្ខមនំមានសារៈសំខាន់ខ្លាំងណាស់សំរាប់ជនជាតិអ៊ីស្រាអែល ពីព្រោះកណ្ឌនេះបានប្រាប់ពួកគេថា ព្រះបានសង្គ្រោះពួកគេចេញពីអេស៊ីព្ទ ដូច្នេះពួកគេត្រូវតែចងចាំថា ពួកគេគឺជារាស្ត្ររបស់ព្រះដែលទ្រង់បានប្រោសលោះ ។ ព្រះបានសង្គ្រោះពួកគេ ដើម្បីអោយពួកគេនឹងថ្វាយបង្គំនិងបំរើទ្រង់ (និក្ខមនំ ៧:៦; ៨:២០; ៩:១; ១០:៣, ៧)។ ព្រះបានប្រោសលោះពួកគេសំរាប់គោលបំណងមួយ ដើម្បីបើកសំដែងសិរីល្អរបស់ទ្រង់ និងប្រើពួកគេជារាស្ត្ររបស់ទ្រង់សំរាប់គោលបំណងមួយ និងសំរាប់តួនាទីមួយនៅក្នុងលោកិយ (និក្ខមនំ ១៩:៤-៦)។ តាមរយៈការធ្វើជាជាតិសាសន៍បរិសុទ្ធមួយ អ៊ីស្រាអែលបានបើកសំដែងព្រះ និងផ្លូវរបស់ទ្រង់ទៅកាន់លោកិយ។

ក្រិត្យវិន័យ ដែលពួកគេបានទទួលនៅស៊ីណាយ គឺជាមូលដ្ឋានគ្រឹះសំរាប់ជីវិតរបស់ពួកគេនៅក្នុងទឹកដីសន្យា។ ក្រិត្យវិន័យនោះពន្យល់អំពីបញ្ញត្តិដែលពួកគេត្រូវគោរពតាម របៀបសាងសង់រោងឧបោសថ ពិធីបុណ្យសាសនាដែលពួកគេត្រូវធ្វើតាម ដូចជាបុណ្យរំលង និងច្បាប់ផ្សេងៗសំរាប់ពួកសង្ឃ។ បើសិនពួកគេស្មោះត្រង់ចំពោះព្រះ គឺបើសិនពួកគេស្មោះត្រង់ចំពោះសម្ពន្ធមេត្រី និងសេចក្តីសញ្ញា នោះពួកគេនឹងបំពេញសំរេចតួនាទីរបស់ពួកគេ (និក្ខមនំ ១៩:៤-៦) ហើយធ្វើជារាស្ត្ររបស់ព្រះរស់នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។

## ៣. តើកណ្ឌនិក្ខមនំទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្ដេច?

ជាមួយកណ្ឌលោកុប្បត្តិ កណ្ឌនិក្ខមនំផ្ដល់នូវមូលដ្ឋានគ្រឹះយ៉ាងសំខាន់សំរាប់ផ្នែកទាំងអស់ទៀតនៅក្នុងព្រះគម្ពីរ នៅក្នុងរបៀបច្រើនជាងរបៀបដែលត្រូវបានពន្យល់នៅទីនេះ។ មានរបៀបខ្លះៗដែលយើងអាចមើលឃើញថា កណ្ឌនិក្ខមនំគឺជាមូលដ្ឋានគ្រឹះមួយសំរាប់អ្វីដែលមានបន្ទាប់។ យើងអាចមើលផ្នែកខុសៗគ្នានៅក្នុងព្រះគម្ពីរបាន។

**កណ្ឌប្រវត្តិសាស្ត្រ យ៉ូស្វេដល់នេហេមា៖** តែងតែមានសំនួរធំៗនៅក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលថា តើអ៊ីស្រាអែលនឹងចងចាំព្រះ ដែលបានសង្គ្រោះពួកគេចេញពីអេស៊ីព្ទឬទេ ហើយពួកគេនឹងស្មោះត្រង់ចំពោះសម្ព័ន្ធមេត្រីឬទេ ពួកគេនឹងស្ដាប់បង្គាប់តាមក្រិត្យវិន័យដែលទទួលបាននៅស៊ីណាយឬទេ ហើយពួកគេនឹងបំពេញសំ   រេចតួនាទី ដែលព្រះបានប្រទានអោយពួកគេនៅក្នុងលោកិយឬទេ (និក្ខមនំ ១៩:៤-៦)?

**កណ្ឌទំនុកដំកើង៖** ទំនុកដំកើងជាច្រើន ឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍ ដែលត្រូវបានកត់ត្រាទុកនៅក្នុងកណ្ឌនិក្ខមនំ ដែលជាសកម្មភាព របស់ព្រះក្នុងការសង្គ្រោះពួកគេចេញពីអេស៊ីព្ទ (៧៨:១១-១៦; ៨០:៨; ១០៥; ១០៦; ១៣៥) ហើយនិងក្រិត្យវិន័យនិងសម្ព័ន្ធមេត្រី ដែលព្រះបានប្រទានអោយនៅស៊ីណាយ (១; ១១៩)។

**ពួកហោរា៖** ពួកហោរានៅក្នុងអ៊ីស្រាអែលមិនគ្រាន់តែជាអ្នកប្រកាសអំពីអនាគតកាលប៉ុណ្ណោះទេ។ ព្រះបានបញ្ជូនពួកគេទៅ ដើម្បីហៅអ៊ីស្រាអែលអោយស្មោះត្រង់ចំពោះព្រះ និងស្មោះត្រង់ចំពោះសម្ព័ន្ធមេត្រី។ ដូច្នេះ ពួកហោរានឹងហៅមនុស្សអោយត្រឡប់មកគោរពតាមក្រិត្យវិន័យ ដែលពួកគេបានទទួលនៅស៊ីណាយ ហើយប្រកាសការវិនិច្ឆ័យរបស់ព្រះសំរាប់ការបរាជ័យមិនស្ដាប់បង្គាប់តាមព្រះបន្ទូល ដែលព្រះបានបើកសំដែងនៅស៊ីណាយរួចហើយ។**ក្រោយការនិរទេស (អែសរ៉ា នេហេមា ហាកាយ សាការី ម៉ាឡាគី)៖** នៅពេលអ៊ីស្រាអែលបានវិលត្រឡប់ពីការនិរទេសវិញគឺដូចជាការចាកចេញថ្មីមួយ។

**ព្រះគម្ពីរសញ្ញាថ្មី និងព្រះយេស៊ូវ៖** សូមមើលបទគម្ពីរ ផ្ទៃរឿង និងព្រឹត្តិការណ៍ខាងក្រោម។ យើងអាចមើលលើបទគម្ពីរ ផ្ទៃរឿង និងព្រឹត្តិការណ៍ខុសៗគ្នានៅក្នុងកណ្ឌនិក្ខមនំ និងរបៀបដែលពួកវាទាក់ទងនឹងបទគម្ពីរដែលមានបន្ទាប់កណ្ឌនិក្ខមនំ។ មានឧទាហរណ៍ខ្លះដូចជា៖

**បុណ្យរំលង និក្ខមនំ ១២៖** បុណ្យរំលងគឺជាពិធីបុណ្យសំខាន់បំផុតនៅក្នុងឆ្នាំរបស់សាសន៍យូដា។ ពួកគេបាននឹកចាំអំពីការវិនិច្ឆ័យរបស់ព្រះលើអេស៊ីព្ទ ហើយអំពីព្រះបានប្រោសលោះពួកគេ។ ព្រះគម្ពីរសញ្ញាថ្មីប្រើបុណ្យរំលងនេះ ដើម្បីបង្ហាញប្រាប់អំពីសេចក្ដីសង្គ្រោះដ៏ធំជាង ដែលយើងបានទទួលបានតាមរយៈព្រះយេស៊ូវ។ ទ្រង់គឺជាកូនចៀមនៃបុណ្យរំលង (១កូរិនថូស ៥:៧)។ យើងទទួលបានសេចក្ដីប្រោសលោះតាមរយៈលោហិតរបស់ព្រះយេស៊ូវ ហើយឥឡូវនេះយើងធ្វើពិធីលៀងព្រះអម្ចាស់ ដើម្បីនឹកចាំអំពីលោហិតរបស់ទ្រង់ ដែលបានសម្រក់សំរាប់យើង។ សេចក្ដីពិតដែលថា គ្រីស្ទបរិស័ទមិនរក្សាតាមពិធីបុណ្យរំលង ហើយបានរក្សាតាមពិធីលៀងព្រះអម្ចាស់

បានបង្ហាញអំពីសារៈសំខាន់នៃការសុគតរបស់ព្រះយេស៊ូវ ហើយសំខាន់ជាងសេចក្ដីសង្គ្រោះចេញពីអេស៊ីព្ទទៅទៀត។

**ម៉ូសេ៖** ម៉ូសេគឺជាហោរាដ៏ធំបំផុតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ប៉ុន្តែអ្នកនិពន្ធក្នុងព្រះគម្ពីរសញ្ញាថ្មីប្រើសេចក្ដីពិតនេះ ដើម្បីបង្ហាញអំពីឧត្តមភាពរបស់ព្រះយេស៊ូវ ដែលទ្រង់ធំជាងម៉ូសេទៅទៀត (ហេព្រើរ ៣:១-៦; ម៉ាថាយ ១៧:១-៥)។

**ក្រិត្យវិន័យ៖** ប៉ុលពន្យល់ថា ដោយសារអំពើបាបទើបព្រះប្រទានក្រិត្យវិន័យ ដើម្បីដឹកនាំយើងទៅរកព្រះគ្រីស្ទ (កាឡាទី ៣:១៩-២៥)។ តាមរយៈក្រិត្យវិន័យ យើងដឹងអំពីអំពើបាបរបស់យើង (រ៉ូម ៣:២០) ហើយដឹងថា យើងត្រូវការសេចក្ដីសង្គ្រោះ ហើយសេចក្ដីសង្គ្រោះអាចមកតាមរយៈតែព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ។

**រោងឧបោសថ៖** រោងឧបោសថបានតំណាងអោយវត្តមាននិងការគ្រប់គ្រងរបស់ព្រះក្នុងចំណោមរាស្ត្ររបស់ទ្រង់។ ដោយសារភាពមិនបរិសុទ្ធរបស់ពួកគេ នោះពួកគេមិនអាចចូលទៅក្នុងទីបរិសុទ្ធបំផុតបានទេ ប៉ុន្តែតាមរយៈការសុគតរបស់ព្រះយេស៊ូវ យើងអាចចូលបាន។ ព្រះយេស៊ូវអង្គទ្រង់ផ្ទាល់ក៏ជារោងឧបោសថ ដែលជាវិហារនិងវត្តមានរបស់ព្រះក្នុងចំណោមយើងផងដែរ (យ៉ូហាន ១:១៤; ២:២០-២១)។

**ពួកសង្ឃ និងព្រះយេស៊ូវ៖** កណ្ឌនិក្ខមនំ (និងកណ្ឌលេវីវិន័យ) ផ្ដល់នូវច្បាប់ផ្សេងៗសំរាប់ពួកសង្ឃប្រព្រឹត្តតាម ប៉ុន្តែអ្នកនិពន្ធក្នុងព្រះគម្ពីរសញ្ញាថ្មីបានពន្យល់ថា ព្រះយេស៊ូវគឺជាសម្ដេចសង្ឃដ៏អស្ចារ្យ ដែលបានសំរេចបាននូវអ្វីដែលពួកសង្ឃក្នុងព្រះគម្ពីរសញ្ញាចាស់មិនដែលសំរេចបានសោះ (ហេព្រើរ ៧-១០)។

**និក្ខមនំ ១៩:៤-៦ និង១ពេត្រុស ២:៩៖** ឥឡូវនេះអស់អ្នកដែលជឿលើព្រះគ្រីស្ទ ទោះជាពួកយូដា ឬពួកសាសន៍ដទៃ មានតួនាទីមួយនៅក្នុងលោកិយ ដែលជាតួនាទីដែលព្រះបានប្រទានអោយអ៊ីស្រាអែលពីដំបូង។ ដោយការបដិសេធនិងការសំឡាប់ព្រះយេស៊ូវ ពួកយូដាបានបាត់បង់នគរ (ម៉ាថាយ ២១:៣៣-៤៦) ប៉ុន្តែតាមរយៈការទទួលយកព្រះយេស៊ូវ យើងបានទទួលនគរ ហើយក្លាយជាពូជសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ។

**ពួកសង្ឃ និងយើង**។ សំរាប់យើងធ្វើជាពួកសង្ឃខុសពីពួកសង្ឃនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ដោយសារព្រះយេស៊ូវ ដែលជាសម្ដេចសង្ឃដ៏អស្ចារ្យរបស់យើងបានបង់ថ្លៃប្រោសលោះហើយ យើងមិនថ្វាយសត្វជាយញ្ញបូជាទេ។ សកម្មភាព ថ្វាយបង្គំរបស់យើងគឺត្រូវថ្វាយខ្លួនរបស់យើងជាយញ្ញបូជារស់ (រ៉ូម ១២:១) ហើយថ្វាយការសរសើរទុកជាគ្រឿងបូជាតាមរយៈព្រះយេស៊ូវ (ហេព្រើរ ១៣:១៥)។

**សម្ព័ន្ធមេត្រី៖** សម្ព័ន្ធមេត្រីគឺជាផ្នែករឿងសំខាន់ខ្លាំងណាស់នៅក្នុងព្រះគម្ពីរ។ នៅស៊ីណាយព្រះមិនគ្រាន់តែបានប្រទានក្រិត្យវិន័យទេ ប៉ុន្តែលើសពីនេះទៅទៀត ព្រះជាម្ចាស់បានចងសម្ពន្ធមេត្រីជាមួយអ៊ីស្រាអែល។ ប៉ុន្តែអ៊ីស្រាអែលមិនបានស្មោះត្រង់ចំពោះសម្ព័ន្ធមេត្រីទេ ដូច្នេះតាមរយៈពួកហោរា ព្រះបានប្រកាសថា ទ្រង់នឹងបង្កើត

សម្ព័ន្ធមេត្រីថ្មីមួយ ដែលនឹងដាក់ក្រិត្យវិន័យនៅក្នុងចិត្តរបស់ពួកគេ (យេរេមា ៣១:៣១-៣៤)។ ព្រះយេស៊ូវគឺព្រះអង្គសម្រុះសម្រួលនៃសម្ព័ន្ធមេត្រីថ្មីនេះ (លូកា ២២:២០; ហេព្រើរ ៧:២២; ៨:៦-១៣)។

**ព្រះនាមរបស់ព្រះ «អញជាព្រះដ៏ជាព្រះ»៖** ព្រះនាមរបស់ព្រះ ដែលត្រូវបានបើកសំដែងទៅកាន់ម៉ូសេ (និក្ខមនំ ៣:១៤) ត្រូវបានអនុវត្តមកកាន់ព្រះយេស៊ូវ (យ៉ូហាន ៨:៥៨)។ (នៅក្នុងភាសាក្រិកព្រះនាមរបស់ព្រះអង្គនៅក្នុងនិក្ខមនំ ៣:១៤ និងព្រះនាមរបស់ព្រះយេស៊ូវនៅក្នុងយ៉ូហាន ៨:៥៨ ដូចគ្នា គឺ Ἐγώ εἰμι ប៉ុន្តែភាពដូចគ្នាបានបាត់បង់នៅក្នុងភាសាខ្មែរ)។ ពួកយូដាបានយល់ថា ការនេះមានន័យថា ព្រះយេស៊ូវកំពុងប្រកាសអង្គទ្រង់ជាព្រះ។

ចំនុចទាំងអស់នេះបង្ហាញថា ជាការសំខាន់ចាំបាច់ដែលយើងអនុវត្តកណ្ឌនិក្ខមនំមកកាន់ខ្លួនរបស់យើងតាមរយៈព្រះយេស៊ូវ។ យើងត្រូវតែប្រយ័ត្នកុំរំលងព្រះព្រះគ្រីស្ទនិងព្រះគម្ពីរសញ្ញាថ្មីអោយសោះ។ យើងបានប្រោសលោះតាមរយៈព្រះគ្រីស្ទ យើងគឺជារាស្ត្ររបស់ព្រះតាមរយៈព្រះគ្រីស្ទ ហើយយើងគឺជាពូជសង្ឃហ្លួង ជាសាសន៍បរិសុទ្ធដោយសារព្រះគ្រីស្ទ។

## ៤. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីព្រះ?

កណ្ឌនិក្ខមនំបង្រៀនយើងថា ព្រះ

- ទតឃើញទាំងអស់។
- មានអំណាចព្រះចេស្តា ហើយគ្រប់គ្រងលើប្រវត្តិសាស្ត្រ។
- មានសិរីរុងរឿង ហើយចង់បើកសំដែងសិរីល្អរបស់ទ្រង់។ ព្រះបានធ្វើអោយផារ៉ោនមានចិត្តរឹង ដើម្បីបើកសំដែងសិរីល្អរបស់ទ្រង់ (និក្ខមនំ ៩:១៦) ហើយបានសង្គ្រោះអ៊ីស្រាអែល ដោយយល់ដល់ព្រះនាមទ្រង់ (ទំនុកដំកើង ១០៦:៨)។ ទ្រង់បានបើកសំដែងព្រះនាមនិងសិរីល្អរបស់ទ្រង់ទៅកាន់ម៉ូសេ។
- មានទំនាក់ទំនងសម្ព័ន្ធមេត្រីជាមួយរាស្ត្ររបស់ទ្រង់ ដូចជាប្តីនិងប្រពន្ធ។ ទ្រង់បាននឹកចាំនិងស្មោះត្រង់ចំពោះសេចក្តីសន្យាសម្ព័ន្ធមេត្រីរបស់ទ្រង់ជាមួយអ័ប្រាហាំ ហើយបានបង្កើតសម្ព័ន្ធមេត្រីមួយទៀតនៅស៊ីណាយ។
- សង្គ្រោះរាស្ត្ររបស់ទ្រង់ ដើម្បីអោយពួកគេនឹងថ្វាយបង្គំនិងបំរើទ្រង់។
- មានសេចក្តីមេត្តាករុណា។ ទោះបីជារាស្ត្ររបស់ទ្រង់រអ៊ូរទាំទាស់នឹងព្រះក៏ដោយ ក៏ទ្រង់បានផ្គត់ផ្គង់ពួកគេដែរ។
- គង់នៅជាមួយរាស្ត្ររបស់ទ្រង់ ហើយទ្រង់ត្រូវតែជាចំនុចស្នូលនៃជីវិតរបស់ពួកគេ។
- គឺជាអង្គវិនិច្ឆ័យ។
- ប្រច័ន្ឌ។ ទ្រង់មិនសព្វព្រះហឫទ័យទេ នៅពេលរាស្ត្ររបស់ទ្រង់អោយអ្វីផ្សេង ឬព្រះដទៃខ្ពស់លើសជាងទ្រង់នោះ (២០:៥; ៣២; ៣៤:១៤)។

- បរិសុទ្ធ ហើយមិនទទួលយកពួកអ្នកមានបាបទេ គឺអំពើបាបត្រូវតែមានការធួននឹងបាប។
- បរិសុទ្ធ ហើយតម្រូវអោយរាស្ត្ររបស់ទ្រង់ត្រូវតែបរិសុទ្ធ។
- មានសិទ្ធិកំណត់អ្វីត្រូវនិងខុស។ មនុស្សមិនមានសិទ្ធិកំណត់ថា អ្វីខុសនិងត្រូវបានទេ គឺមានតែព្រះទេដែលមានសិទ្ធិនិងបើកសំដែងអ្វីត្រូវឬខុសតាមរយៈព្រះបន្ទូលរបស់ទ្រង់។
- គឺជាព្រះពិតតែមួយ ហើយព្រះដទៃទាំងអស់ទៀតគឺសុទ្ធតែក្លែងក្លាយទាំងអស់។ គ្រោះកាចបង្ហាញថា ទ្រង់គឺជាព្រះដ៏ពិត។
- ស្អប់ការថ្វាយបង្គំរូបព្រះ។
- សមនឹងទទួលបានការថ្វាយបង្គំ ហើយបើកសំដែងអំពីការថ្វាយបង្គំដែលទ្រង់សព្វព្រះទ័យ។
- ប្រទានសមត្ថភាពដល់មនុស្សអោយបំពេញកាតព្វកិច្ច ដែលទ្រង់បានប្រទានអោយពួកគេ (ដូចជា ម៉ូសេ បេតសាលាល និងអូហូលីអាប់)។
- យកព្រះទ័យទុកដាក់ចំពោះគ្រប់ផ្នែកទាំងអស់នៅក្នុងសង្គម។ ព្រះបានប្រទានក្រិត្យវិន័យដល់អ៊ីស្រាអែលដើម្បីដោះស្រាយបញ្ហាជាច្រើននៅក្នុងសង្គម។ យើងមិនមែនជាអ៊ីស្រាអែលនៅក្នុងទឹកដីសន្យាទេ ដូច្នេះយើងត្រូវតែប្រយ័ត្នក្នុងការអនុវត្តក្រិត្យវិន័យនៅក្នុងសព្វថ្ងៃនេះ ប៉ុន្តែនៅមានគោលការណ៍ខ្លះៗដែលយើងត្រូវអនុវត្តតាមផងដែរ។
- មិនសព្វព្រះទ័យចំពោះមនុស្សដែលរអ៊ូរទាំទាស់នឹងទ្រង់។

## ៥. តើកណ្ឌនេះបង្រៀនយើងអ្វីអំពីមនុស្ស

- មនុស្សបះបោរប្រឆាំងនឹងព្រះ។
- មនុស្សមានចិត្តសាហាវ ហើយគៀបសង្កត់រាស្ត្ររបស់ព្រះជាញឹកញាប់។
- មនុស្សថ្វាយបង្គំរូបព្រះ។ យើងដើរតាមរូបព្រះផ្សេងៗជាជាងការដើរតាមព្រះដ៏ពិត។
- មនុស្សបំភ្លេចព្រះដោយងាយស្រួល។
- មនុស្សដែលមានជំនឿសរសើរដំកើងព្រះជាម្ចាស់ដោយសារសេចក្ដីល្អរបស់ព្រះ (និក្ខមនំ ១៥:១-២១)។